**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

លេខ ៥៩៦៧ កសក

# សេចក្តីជូនដំណឹង
## ស្តីពី
## ការរំលឹកអំពីការបញ្ឈប់សកម្មភាពចិញ្ចឹមត្រីឆ្តោ និងត្រីរ៉ស់

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមប្រកាសជូនដំណឹងដល់គណៈអភិបាលរាជធានី ខេត្ត អាជីវករ និងប្រជាពលរដ្ឋទូទាំងប្រទេសឱ្យបានជ្រាបថា កន្លងមករាជរដ្ឋាភិបាល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានសម្រេចបញ្ឈប់សកម្មភាពចិញ្ចឹមត្រីឆ្តោ ត្រីរ៉ស់ និងបានអំពាវនាវដល់អាជីវករ ប្រជាពលរដ្ឋទូទៅមេត្តាបង្វែរទិសដៅពីការចិញ្ចឹមត្រីឆ្តោ និងត្រីរ៉ស់ ទៅចិញ្ចឹមត្រីប្រភេទផ្សេងៗវិញ។

ថ្មីៗនេះ សកម្មភាពចិញ្ចឹមត្រីឆ្តោ និងត្រីរ៉ស់បានកកើតឡើងវិញនៅតាមបណ្តាខេត្តមួយចំនួន ទោះបីរាជរដ្ឋាភិបាល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់បានធ្វើការទប់ស្កាត់ជាបន្តបន្ទាប់ និងបានធ្វើការផ្សព្វផ្សាយពីផលប៉ះពាល់ដល់ធនធានជលផល ដោយសារតែការនេសាទកូនត្រីពីបឹង ទន្លេធម្មជាតិសម្រាប់ផ្តល់ជាចំណីឱ្យត្រីឆ្តោ និងត្រីរ៉ស់ចិញ្ចឹមក៏ដោយ។

ដើម្បីចៀសវាងនូវផលប៉ះពាល់ដ៏ធ្ងន់ធ្ងរដល់ធនធានធម្មជាតិ និងលុបបំបាត់ឱ្យបាននូវសកម្មភាពចិញ្ចឹមត្រីឆ្តោ ត្រីរ៉ស់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមរំលឹកដល់គណៈអភិបាលរាជធានី ខេត្ត មេត្តាបន្តចាត់វិធានការឱ្យបានម៉ឺងម៉ាត់លុបបំបាត់លើរាល់ការចិញ្ចឹមត្រីឆ្តោ ត្រីរ៉ស់ ហើយសង្ឃឹមយ៉ាងមុតមាំថា បងប្អូនអាជីវករក៏ដូចជាប្រជាពលរដ្ឋនឹងសហការគ្នាបញ្ឈប់សកម្មភាពចិញ្ចឹមត្រីឆ្តោ ត្រីរ៉ស់ ដោយចូលរួមចំណែកក្នុងការអនុវត្តច្បាប់ និងការពារធនធានជលផល ឱ្យបានគង់វង្សយូរអង្វែង។

រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៥

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**ចម្លងជូនៈ**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងបរិស្ថាន "ដើម្បីជូនជ្រាបជាព័ត៌មាន"
- ក្រសួងព័ត៌មាន "ដើម្បីជួយផ្សព្វផ្សាយ"
- រដ្ឋបាលជលផល
- គ្រប់អធិការដ្ឋានរដ្ឋបាលជលផល
- គ្រប់ខណ្ឌរដ្ឋបាលជលផល

"ដើម្បីអនុវត្ត"
- មន្ទីរកសិកម្ម រាជធានី ខេត្ត

"ដើម្បីជ្រាប"
- ឯកសារ កាលប្បវត្តិ